## មជ្ឈមណ្ឌលឯកសារកម្ពុជា

## គម្រោងស្តីពីការសិក្សាប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ
## វគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន
## ស្តីពីការបង្រៀន «ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

### លក្ខខណ្ឌសម្រាប់គ្រូបង្គោលថ្នាក់ខេត្ត ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលគ្រូមូលដ្ឋាន

***លក្ខខណ្ឌទូទៅ***

- *គ្រូបង្គោលថ្នាក់ខេត្ត ត្រូវអញ្ជើញមកដល់ទីតាំងបណ្តុះបណ្តាលឲ្យបានមួយថ្ងៃ មុនថ្ងៃបណ្តុះបណ្តាល ។*
- *ត្រូវចូលរួមប្រជុំនៅវេលាម៉ោង៧រសៀល មួយថ្ងៃមុនថ្ងៃបណ្តុះបណ្តាល ដើម្បីពិនិត្យមើលកម្មវិធី តួនាទី និងការទទួលខុសត្រូវ ។*
- *ក្នុងរយៈពេលនៃការបណ្តុះបណ្តាល ត្រូវអញ្ជើញមកដល់ទីតាំងបណ្តុះបណ្តាលឲ្យបាន១៥នាទី មុនពេលចាប់ផ្តើមជារៀងរាល់ថ្ងៃ ។*
- *នៅរៀងរាល់ពេលល្ងាចនៃថ្ងៃនីមួយៗ ត្រូវចូលរួមប្រជុំពិនិត្យមើលបញ្ហាប្រឈម និងកម្មវិធីសម្រាប់ថ្ងៃបន្ទាប់ ។*
- *ត្រូវផ្តល់ការណែនាំច្បាស់លាស់ និងគ្រប់គ្រងពេលវេលាឲ្យមានប្រសិទ្ធិភាព ។*
- *ត្រូវរៀបចំកិច្ចតែងការបង្រៀនឲ្យបានត្រឹមត្រូវ មុនពេលឡើងបង្រៀន ។*
- *ត្រូវកត់ត្រាទុកនូវបញ្ហាប្រឈម ដែលខ្លួនបានជួបប្រទះក្នុងថ្ងៃនីមួយៗ ។*
- *មិនត្រូវពិសារបារីនៅក្នុងបរិវេណបណ្តុះបណ្តាល ។*
- *សូមបិទសម្លេងទូរស័ព្ទក្នុងកំឡុងពេលសិក្សា ។*
- *សូមកុំជជែកគ្នាក្នុងកំឡុងពេលសិក្សា ។*
- *អញ្ជើញមកទីតាំងបណ្តុះបណ្តាលឲ្យបានទៀតទាត់ តាមពេលវេលាដែលបានកំណត់ ។*
- *សូមអាន (១) សៀវភៅប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (២) សៀវភៅណែនាំសម្រាប់គ្រូបង្រៀន និង (៣) ឯកសារបណ្តុះបណ្តាលផ្សេងៗទៀតឲ្យបានចប់សព្វគ្រប់ មុនអញ្ជើញមកទីតាំងបណ្តុះបណ្តាល ។*
- *សូមអានកម្មវិធីបណ្តុះបណ្តាលសម្រាប់ថ្ងៃនីមួយៗឲ្យបានយល់ច្បាស់ ។*
- *គោរពគ្នាទៅវិញទៅមកនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល ។*

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

- ត្រូវគោរពសិទ្ធិរបស់ស្ត្រី ។ មិនត្រូវនិយាយឬសំដែងកាយវិការណាមួយ ដែលមានលក្ខណៈមើលងាយឬមានលក្ខណៈជាការបៀតបៀនផ្លូវភេទ ។
- ត្រូវគោរពចំពោះសិទ្ធិរបស់អ្នកដែលគោរពជំនឿសាសនាផ្សេងៗគ្នា និងជៀសវាងសកម្មភាព ឬកាយវិការ ដែលមានលក្ខណៈជាការរើសអើងពូជសាសន៍ ។
- ត្រូវមានការទទួលខុសត្រូវ និងគោរពវិន័យ ។

**ថវិកាឧបត្ថម្ភ**

- មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលខុសត្រូវ ក្នុងការចំណាយទៅលើថ្លៃធ្វើដំណើរ ដែលមិនអាចមានភាពសុក្រិតឬដូចគ្នាបានមួយភាគរយទេ ។ លោកគ្រូអ្នកគ្រូទទួលបានថវិកាបន្ថែមចំនួន២០ដុល្លារសហរដ្ឋអាមេរិកក្នុងមួយថ្ងៃ សម្រាប់ការស្នាក់នៅនិងការហូបចុក ។
- ថវិកានឹងត្រូវបានបើកជូនសម្រាប់រយៈពេល៨ថ្ងៃពេញ គឺមួយថ្ងៃសម្រាប់ការធ្វើដំណើរទៅកាន់មណ្ឌលបណ្តុះបណ្តាលនិងការចូលរួមប្រជុំពេលល្ងាច និង៧ថ្ងៃសម្រាប់វគ្គបណ្តុះបណ្តាល ។ លោកគ្រូអ្នកគ្រូដែលមិនបានចូលរួមប្រជុំនៅថ្ងៃទីមួយ នឹងទទួលបានថវិកាសម្រាប់តែរយៈពេល៧ថ្ងៃតែប៉ុណ្ណោះ ។
- ថវិកាដែលផ្តល់ជូន គឺដើម្បីជួយទ្រទ្រង់ដល់ការស្នាក់នៅនិងការបំពេញបេសកកម្មរបស់លោកគ្រូអ្នកគ្រូ មិនមែនជាការប្រើប្រាស់ថវិការដើម្បីអញ្ជើញលោកគ្រូអ្នកគ្រូឲ្យចូលរួមសិក្ខាសាលា ឬជាថ្នូរនឹងចំណេះដឹងឬបទពិសោធន៍តាមរយៈសិក្ខាសាលានេះទេ ។
- ថវិកានឹងត្រូវបានបើកជូននៅថ្ងៃចុងក្រោយនៃវគ្គបណ្តុះបណ្តាល ។

**សម្រាប់ព័ត៍មានបន្ថែម សូមទាក់ទងមកលោក វ៉ាន់ថាន់ ពៅដារ៉ា ០១២ ៨៤៦ ៥២៦ ។**